**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

# របាយការណ៍

## ស្តីពី

## ការផ្តល់ចំណេះដឹងផ្នែកតាមដាន និងវាយតម្លៃក្នុងការអនុវត្តកម្មវិធីអេដស៍ និងកាមរោគ

ថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៤ ដោយការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិច្ឆា** ប្រធានមជ្ឈមណ្ឌលជាតិ **លោកវេជ្ជបណ្ឌិត លឹម យី** អនុប្រធានមជ្ឈមណ្ឌលជាតិ រួមអមដំណើរដោយមន្ត្រីជំនាញនៃការិយាល័យបច្ចេកទេស និងផ្នែកជំនាញពាក់ព័ន្ធ នៃមជ្ឈមណ្ឌលជាតិបានដឹកនាំរៀបចំសិក្ខាសាលាស្តីពី ការពង្រឹងចំណេះដឹងផ្នែកតាមដាន និងវាយតម្លៃ ក្នុងការអនុវត្តកម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២៤ នៅភូមិគ្រឹះនាងគង្ហីង ខេត្តកំពង់ចាម។ វគ្គសិក្ខាសាលានេះក្រោមអធិបតីភាព របស់ **លោកវេជ្ជបណ្ឌិត លឹម យី** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ **លោកវេជ្ជបណ្ឌិត សេង សុផារុណ** អនុប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពងចាម ក្នុងរយៈពេល ៣០ នាទី នៃការសំណេះសំណាលរបស់គណៈធិបតី លោកបានមានចំណាប់អារម្មណ៍ថាលោកមានក្តីសប្បាយរីករាយណាស់ដែលបានចូលរួមក្នុងវគ្គសិក្ខាសាលាដែលវគ្គនេះមានការចូលរួមពីលោក លោកស្រីប្រធានកម្មវិធីអេដស៍ ក្នុងការកសាងសមត្ថភាពក៏ដូចជាពង្រឹងនូវចំណេះដឹងបន្ថែមក្នុងការរួមចំណែកបន្ថែមលើការងារការតាមដាន និងវាយតម្លៃ ក្នុងកម្មវិធីអេដស៍ និងកាមរោគប្រកបដោយប្រសិទ្ធិភាព និងសុក្រិត្យភាពស្របទៅនឹងកម្មវិធីថ្នាក់ជាតិ ហើយលោកក៏បានផ្តាំផ្ញើអោយសិក្ខាកាមត្រូវលើកកំពស់ស្មារតី និងយកចិត្តទុកដាក់ ក្នុងការចូលរួមឱ្យបានស៊ីជម្រៅ និងយល់កាន់តែច្បាស់អំពីជំនាញផ្សេងៗ។ នៅចុងបញ្ចប់លោកក៏បានជូនពរដល់សិក្ខាកាមទាំងអស់ដែលចូលរួមក្នុងវគ្គនេះឱ្យជួបតែសេចក្តីសុខ និងមានសុខភាពល្អដើម្បីចូលរួមជាប្រយោជន៍ក្នុងវគ្គសិក្ខាសាលានេះរួមប្រកាសបើកវគ្គសិក្ខាសាលានៅវេលាម៉ោង ៩.០០នាទី ។

**គោលបំណងរួមនៃសិក្ខាសាលាគឺ៖**

1/ យល់ពីគោលការណ៍ តាមដាន និងវាយតម្លៃ

2/ យល់ពីសូចនាករ និងអាចជ្រើសរើសសូចនាករសមស្របសម្រាប់ការអនុវត្តកម្មវិធីអេដស៍ថ្នាក់ខេត្ត

3/ យល់ពីក្របខ័ណ្ឌតាមដានការអនុវត្តកម្មវិធីអេដស៍ និងកំណត់យក M&E Framework សម្រាប់ខេត្ត

4/ យល់ពីការគ្រប់គ្រង និងគុណភាពទិន្នន័យ

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីតំណាង MOH-LIT, ផ្នែកជំនាញនៃមជ្ឈមណ្ឌលជាតិ លោក លោកស្រី ប្រធានកម្មវិធីអេដស៍ និងកាមរោគ ២៥ រាជធានី ខេត្ត និងក្រុមការងារបច្ចេកទេសដែលពាក់ព័ន្ធ ។



| ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៤ Day 1: June 17, 2024 | | |
|---|---|---|
| **ពេលវេលាTime** | **ប្រធានបទ subjects** | **Presenter/Facilitator/Moderators** |
| **7:30-8:30** | **ការចុះឈ្មោះ** (Registration) | NCHADS Accountant/admin. staff |
| **8:30-9:00** | កម្មវិធីបើកសិក្ខាសាលា (Opening ceremony)<br>កិច្ចស្វាគមន៍ដោយ:<br>- **លោកវេជ្ជ. សេង សុផារុន** អនុប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម<br>ពិធីបើកសិក្ខាសាលា<br>- **លោកវេជ្ជ. លឹម ឃី** អនុប្រធាន NCHADS | កញ្ញា ជុំ ស្រីម៉ុច |
| **09:00-09:20** | សំរាក Coffee Break | |
| **09:20-09:10** | - ការសង្ខេបកាលវិភាគ និងគោលបំណងនៃសិក្ខាសាលា | លោកវេជ្ជ. គឹម ប៊ុណ្ណា ប្រធានការិ. បច្ចេកទេស NCHADS |
| **09:10-10:00** | - បង្ហាញអំពីសមិទ្ធផលត្រីមាសទី ១ ឆ្នាំ ២០២៤ ក្នុងការអនុវត្តកម្មវិធីអេដស៍ខេត្ត | តំណាងកម្មវិធីអេដស៍ខេត្តកំពង់ធំ និងខេត្តប៉ៃលិន |
| **10:00-10:30** | - ការសង្ខេបសមិទ្ធិផលត្រីមាសទី ១ ឆ្នាំ ២០២៤ នៃការអនុវត្តកម្មវិធីអេដស៍ក្នុងវិស័យសុខាភិបាល | លោកវេជ្ជ. គឹម ប៊ុណ្ណា ប្រធានការិ. បច្ចេកទេស NCHADS |
| **10:30-11:30** | - គោលការណ៍ តាមដាន និងវាយតំលៃ | លោកវេជ្ជ. លឹម ឃី, អនុប្រធាន NCHADS |

| | | |
|---|---|---|
| **11:30-14:00** | **សំរាក សំរាប់អាហារថ្ងៃត្រង់ Lunch Break** | |
| **14:00-14:30** | - ស្វែងយល់ពី បច្ចុប្បន្នភាពការប្រើប្រាស់ MPI and DHIS2 | លោក ចោង ដុល្លា DMU Officer |
| **14:30-15:00** | - ការគ្រប់គ្រង និងគុណភាពទិន្នន័យ | លោកវេជ្ជ. ការឿន ចិត្រា, អនុប្រធានការិ. បច្ចេកទេស NCHADS |
| **15:00-15:30** | **សំរាក Coffee Break** | |
| **15:30-16:00** | - ការកំណត់សូចនាករសម្រាប់កម្មវិធីបង្ការ និងថែទាំ ជំងឺអេដស៍ ៩៥-៩៥-៩៥<br>- ការរៀបចំបង្កើតក្របខ័ណ្ឌនៃគម្រោងតាមដាន និងវាយតម្លៃ | លោកវេជ្ជ. គឹម ប៊ុណ្ណា ប្រធានការិ. បច្ចេកទេស NCHADS |
| **16:00-17:00** | សរុបរបាយការណ៍នៃសិក្ខាសាលា<br><br>ពិធីបិទនៃកិច្ចប្រជុំ | លោកវេជ្ជ. គឹម ប៊ុណ្ណា ប្រធានការិ. បច្ចេកទេស NCHADS<br><br>លោកវេជ្ជ. លឹម យី អនុប្រធាន NCHADS |

ការពិភាក្សា ដំណោះស្រាយ និងការផ្តល់មតិបានលើកឡើងក្នុងកំឡុងពេលសិក្ខាសាលា ជាពិសេសបន្ទាប់ការបង្ហាញនីមួយៗ ដែលមានការសង្ខេបដូចខាងក្រោម៖

- ពង្រឹងការងារតាមដានអ្នកជំងឺមកទទួលសេវាតាមកាលកំណត់ ដើម្បីកាត់បន្ថយករណីបោះបង់ការព្យាបាលលើសពី ២៨ថ្ងៃ
- ពង្រឹង និងបង្កើនការផ្តល់ការព្យាបាលបង្ការរបេង សម្រាប់អ្នកជំងឺអេដស៍
- ការបង្កើត user name សម្រាប់កម្មវិធីអេដស៍ខេត្ត នីមួយៗ ដើម្បីអាច ចូលមើលនិងយកទិន្នន័យនៅក្នុង DHIS2
- បានបង្កើត គម្រោងតាមដាន និងវាយតម្លៃ (M&E Frame work) សម្រាប់អនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ រាជធានីខេត្ត បានជ្រើសរើសនិងបញ្ចូល សូចនាករដាក់ក្នុង M&E Framework ឆ្នាំ ២០២៤ ដែលមាន សូចនាករ ចំនួន ១៥ ទាក់ទងនឹង ៩៥ ទី ១ ចំនួន ០៨ ទាក់ទងនឹង ៩៥ ទី ២ (ដោយបញ្ចូលសូចនាករសម្រាប់វាស់វែង អ្នកជំងឺអេដស៍ ត្រឡប់មកទទួលសេវា វិញ បន្ទាប់ពី បោះបង់ព្យាបាល លើសពី ២៨ ថ្ងៃ ) និងសូចនាករ ចំនួន ០២ ទាក់ទងនឹង ៩៥ ទី ៣។ ដោយឡែក កម្មវិធីអេដស៍ខេត្តនីមួយៗអាចបញ្ចូលបន្ថែមនូវសូចនាដែលចាំបាច់សម្រាប់វាស់វែងសម្រាប់អនុវត្តកម្មវិធីអេដស៍ខេត្ត។

ចុងបញ្ចប់នៃសិក្ខាសាលា **លោកវេជ្ជបណ្ឌិត លឹម យី** បានធ្វើការសរុបរបាយការណ៍នៃសិក្ខាសាលា និងពិធីបិទនៃសិក្ខាសាលានេះលោកបានសំណូមពរឱ្យគ្រប់កម្មវិធីអេដស៍ថ្នាក់ខេត្ត និងផ្នែកពាក់ពន្ធ័ទាំងអស់ធ្វើយ៉ាងណាយកចិត្តទុកដាក់ស្វែងយល់បន្ថែមនូវសូចនាករ សំខាន់ៗរបស់កម្មវិធីឱ្យបានច្បាស់ និងពន្លឿនការអនុវត្តន៍ នឹងដោះស្រាយសកម្មភាពប្រឈមនានាឱ្យបានប្រសើរជាពិសេសជុំវិញការងារពាក់ព័ន្ធទៅនឹងការងារសកម្មភាពលើផែនការសកម្មភាពរបស់ខេត្តនីមួយៗដោយធ្វើ

យ៉ាងណាបានដាក់អនុវត្តន៍បានកាន់តែឆាប់រហ័សជាអតិបរមា និងជំរុញបន្ថែមឱ្យយកចិត្តទុកក្នុងការងារការអនុវត្តការងារប្រចាំថ្ងៃឱ្យបានកាន់តែល្អប្រសើរ។ សិក្ខាសាលានេះត្រូវបានបញ្ចប់ដោយជោគជ័យតាមកម្មវិធីដែលបានគ្រោងទុកក្រោមបរិយាកាសយោគយល់គ្នានិងសាមគ្គីភាព នៅ ថ្ងៃខែឆ្នាំ ដដែល៕